# តម្លៃ មុឹងម៉ាត់ ឱ្យបាន យូរអង្វែង

ប្រយោគ នេះ លោក ប៉ុណ្ណចន្ទ ម៉ុល គាត់ សរសេរ នៅ ឆ្នាំ ១៩៧៣ នៅ ក្នុង សៀវភៅ របស់ គាត់ « ចរិត ខ្មែរ » ជា ការ រំឭក ដល់ កុលបុត្រ - កុលធីតា ខ្មែរ ថា បើ ធ្វើ អ្វី មួយ ដើម្បី រក ផលប្រយោជន៍ ឱ្យ ជាតិ គួរ ធ្វើ ឱ្យបាន មុឹងម៉ាត់ ហើយ ឱ្យបាន យូរអង្វែង។ ព្រោះ គាត់ សង្កេតឃើញ ថា ខ្មែរយើង ព្រោះ តែ ធូរស្លែត ស្លែត ព្រាលែង អីចឹងហើយ បាន ជា ពិបាក គេចផុត ពី កញ្ជះ  បរទេស ទាំង រាស្ត្រ ទាំង នាម៉ឺន នោះ។ ដូច សព្វថ្ងៃ របប នៅ ភ្នំពេញ គេ នាំ គ្នា បំប៉ោង គំនិត « អរគុណ សន្តិភាព » ដែល គេ ទុក ជា កត្តា គោល នៃ ការរីកចំរើន របស់ ប្រជាជាតិ ហើយ សូម ឱ្យ ប្រជាជន ខ្មែរ ថែ រក្សា ឱ្យបាន មុឹងម៉ាត់ និង  ជា ចិរភាព។ ការអំពាវនាវ នេះ ធ្វើ សំរាប់ រំឭក ខួប ថ្ងៃ ទី ៧ មករា ឆ្នាំ ១៩៧៩ វា បង្ហាញ ឱ្យឃើញ ថា របប នេះ វា គ្មាន ភាពមុឹងម៉ាត់ ដែល អាច ឱ្យ ប្រជាពលរដ្ឋ ខ្មែរ មាន មោទនភាព ចំពោះ ខ្លួន ដែល អាច ទុក ជា អ្នក សំណង់ នៃ សន្តិភាព ក្រៅ តែ ពី រំឭក អរគុណ ដល់ កងទ័ព យួន ជា ចិរកាល ហើយ គិត តែ ពី សង បំណុល យួន ព្រោះ យួន គេ ទុក ជា បំណុល នៃ ឈាម របស់ យោធា យួន ដែល បាន មក ស្លាប់ នៅ លើ ទឹកដី កម្ពុជា ដើម្បី រំដោះ ប្រជាជន ខ្មែរ ពី របប ជន

ឃាត។ ចំណែង[1] រវាង ប្រជាពលរដ្ឋ ខ្មែរ និង របប ភ្នំពេញ គឺ អ្នកមានគុណ និង អ្នកអរគុណ ដែល អ្នក ទី១ បង្ខំ ឱ្យ អ្នក ទី ២ រក្សា អរគុណ កងទ័ព យួន ឱ្យបាន មុឹងម៉ាត់ និង ជា ចិរកាល នោះឯង ដែល គេ យក ថ្ងៃ ទី ៧ មករា ជា និមិត្តរូប នៃ សន្តិភាព នៅ ក្រោម ម្លប់ នៃ បារមី របស់ កងទ័ព យួន។

តាំងតែ ពី ខ្ញុំ ធំ ដឹងក្តី រហូត មក ដល់ ចាស់ ជិតស្លាប់ ខ្ញុំ ឮ តែ ខ្មែរយើង និយាយ រំឭក គ្នា ទៅវិញ ទៅមក ពី គ្រោះថ្នាក់យួន តែ វា គ្រាន់ តែ បាន និយាយ តែ គ្មាន ចិត្ត មុឹងម៉ាត់ ឱ្យបាន យូរអង្វែង ស្វែង រក ឧបាយស្រ័យ ណា មួយ ដើម្បី ការពារ គ្រោះថ្នាក់ នោះ ឡើយ។ សព្វថ្ងៃ គ្រោះថ្នាក់យួន វា ទៅ ជា ភាពធម្មតា សំរាប់ ខ្មែរ ព្រោះ ប្រជាជន យួន គេ មក រស់នៅ រាប់ លាន នាក់ នៅ គ្រប់ ទីកន្លែង នៅក្នុង ស្រុកខ្មែរ ដែល មិន អាច ទុក ជា គ្រោះថ្នាក់ បាន ទៀត ឡើយ ដ្បិត ខ្មែរ មាន ចិត្ត ធូរស្តែត នៅ ចំពោះមុខ បាតុភូត នេះ ដែល មិន អាច នឹង ជឿ បាន។ ព្រះរាជាណាចក្រ កម្ពុជា ជា កោះ សន្តិភាព សំរាប់ ជនជាតិយួន ព្រោះ មាន អាជ្ញាធរ ខ្មែរ ជា អ្នកការពារ និង ជួយ ឧបត្ថម្ភ គ្រប់ បែប យ៉ាង, រីឯ ជនខ្មែរ, ជា យុវជន ពេញ កម្លាំង ចលករ សំរាប់ ជាតិ, ជា ម្ចាស់ ស្រុក វិញ បែរ ជា នាំ គ្នា ចំណាក ស្រុក ទៅ ធ្វើ ឈ្នួល ជា ពលករ នៅ បរទេស ដើម្បី រស់ ទៅវិញ។ ហេតុអ្វី ? នៅ សម័យ ដើម រាស្ត្រខ្មែរ នាំ គ្នា រត់ គេច កងទ័ព សៀម

[1] ចំណែង : ទំនាក់ទំនង។

ព្រោះ ខ្លាច សៀម ចាប់ យក ទៅ ស្រុក គេ ដើម្បី ធ្វើ កំណែន សំរាប់ ផលប្រយោជន៍ របស់ គេ ក្នុង ឋានះ ជា រាស្ត្រទាស, តែ សព្វថ្ងៃ ផ្ទុយ ទៅវិញ ជនខ្មែរ នាំ គ្នា រុល ចូល ស្រុកសៀម ដើម្បី សុំរស់ ព្រោះ មើលឃើញ ថា ស្រុក គេ វា មាន សន្តិភាព ពិត។ តើន័យ សន្តិភាព នៅ ស្រុកខ្មែរ ដែល របប ភ្នំពេញ គេ ទន្ទេញ ចាំរត់មាត់ វា មាន ខ្លឹមសារ បែប ណា ដែរ ? ប្រហែល ជា ខ្មែរយើង គ្មាន ចិត្ត ម៉ឺងម៉ាត់ ឱ្យបាន យូរអង្វែង តាំង ពី បុរាណកាល មក ដើម្បី ការពារ ប្រជាជាតិខ្មែរ ដែល នាំ ឱ្យ បរទេស គេ អាច ទាញ យក ចំណេញ ពី ស្រុកខ្មែរ បាន ងាយស្រួល បំផុត។ ដូចយ៉ាង ពួក ចិន នាំ ល្បែង ស៊ីសង ចូល ស្រុក ខ្មែរយើង នាំ គ្នា អរ ថា ចិន មក ជួយ ខ្មែរ ព្រោះ ថា ចិន គេ ឱ្យ រដ្ឋខ្មែរ ខ្ចី លុយ យ៉ាងងាយស្រួល ហើយ ខ្មែរយើង គិត តែ ពី នាំ គ្នា អរ នៅ ពេល ណា ៗ ថា បរទេស គេ ជួយ ខ្មែរ ដោយ ភ្លេច គិត ថា មាន តែ ទឹកចិត្ត ម៉ឺងម៉ាត់ ឱ្យបាន យូរអង្វែង របស់ ខ្មែរ ខ្លួន ឯង ទើប ខ្មែរ អាច ជួយ សង្គ្រោះ ខេមរៈជាតិ បាន៕